MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

# សេចក្តីថ្លែងការណ៍របស់ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស
# លោកស្រី មីសែល បាសែឡេត (Michelle Bachelet)
# ទីក្រុងហ្សឺណែវ ៦ ធ្នូ ២០១៨

*នៅខណៈពេលដែលយើងប្រារព្ធខួបគម្រប់ ៧០ ឆ្នាំ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសមិទ្ធផលជាច្រើនដែលកើតឡើងដោយសារឯកសារដំបូងគេក្នុងប្រវត្តិសាស្ត្រមួយនេះ លោកស្រី បាសែឡេត ឧត្តមស្នងការសិទ្ធិមនុស្ស បានអំពាវនាវឲ្យ «ពួកយើងម្នាក់ៗបំពេញតួនាទីខ្លួនឯងដើម្បីប្រែក្លាយជីវិតរបស់យើងទៅជាសុបិនដ៏ស្រស់បំព្រង ស្របតាមស្មារតីនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស»។ សេចក្តីថ្លែងការណ៍ខាងក្រោមនេះ អាចរកបានជាភាសារបស់ អ.ស.ប នៅលើគេហទំព័រ www.ohchr.org នៅថ្ងៃស្អែកមុនពេលការមកដល់នៃទិវាសិទ្ធិមនុស្ស នាថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៨ ។*

ទីក្រុងហ្សឺណែវ (ថ្ងៃទី ៦ ខែធ្នូ ឆ្នាំ ២០១៨) - នៅថ្ងៃ ១០ ធ្នូ យើងប្រារព្ធខួបគម្រប់ ៧០ ឆ្នាំ នៃឯកសារដ៏វិសេសវិសាលមួយ គឺសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា ឯកសារនេះនៅតែមានសារៈសំខាន់ចាប់តាំងពីពេលអនុម័តកាលពី ៧០ ឆ្នាំមុន រហូតដល់ទល់ពេលបច្ចុប្បន្ន។

ម្យ៉ាងវិញទៀត ឯកសារនេះកាន់តែមានសារៈសំខាន់ខ្លាំងឡើងៗអស់កាលជាច្រើនទសវត្សកន្លងមក ដោយសារឯកសារនេះបានប្រែក្លាយពីអត្ថបទសន្និសញ្ញាធម្មតាទៅជាសំណុំនៃបទដ្ឋានពិតប្រាកដដែលបានផ្សព្វផ្សាយស្ទើរតែគ្រប់វិស័យនៅក្នុងច្បាប់អន្តរជាតិ។

ឯកសារនេះនៅតែអាចឆ្លងកាត់ព្រឹត្តិការណ៍ផ្សេងៗអស់រយៈពេលជាច្រើនឆ្នាំ និងការអភិវឌ្ឍយ៉ាងខ្លាំងនៃបច្ចេកវិទ្យាថ្មីនិងការអភិវឌ្ឍសង្គម នយោបាយ និងសេដ្ឋកិច្ច ដែលអ្នកតាក់តែងឯកសារនេះ មិនអាចព្យាករណ៍បាននាពេលបង្កើតដំបូង។

ទស្សនាទនៃឯកសារនេះ គឺជាមូលដ្ឋានគ្រឹះ ដែលអាចយកទៅអនុវត្តចំពោះគ្រប់ការវិវត្តន៍នានា។ សេចក្តីប្រកាសជាសកលបានផ្តល់ឲ្យយើងនូវគោលការណ៍ទាំងឡាយ ដែលយើងត្រូវការដើម្បីគ្រប់គ្រងបញ្ហាសិប្បនិម្មិត និងពិភពឌីជីថល។

ឯកសារនេះកំណត់ក្របខ័ណ្ឌនៃការឆ្លើយតបដែលអាចត្រូវបានប្រើប្រាស់ ដើម្បីទប់ទល់ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុទៅលើមនុស្ស មិនត្រឹមតែនៅលើភពផែនដីប៉ុណ្ណោះទេ។

ឯកសារនេះ ផ្តល់ឲ្យយើងរាល់គ្នានូវមូលដ្ឋាន ដើម្បីធានាសិទ្ធិស្មើគ្នាសម្រាប់ក្រុមមនុស្ស ដូចជា ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា (LGBTI) ដែលមានពួកគេតិចតួចណាស់ ហ៊ានបង្ហាញអត្តសញ្ញាណខ្លួនឯងកាលពីអំឡុងឆ្នាំ១៩៤៨។

មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិនិងសេរីភាពទាំងអស់ ដែលមានចែងក្នុងសេចក្តីប្រកាសជាសាកលនេះ «ដោយគ្មានការប្រកាន់បែងចែកពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតសង្គម ឬជាតិពិន្ទុ ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃៗទៀតឡើយ។

ពាក្យពេចន៍ចុងក្រោយនៃឃ្លានោះ គឺ «ស្ថានភាពដទៃផ្សេងទៀត»ដែលជាញឹកញាប់ត្រូវបានគេលើកឡើងដើម្បីរាប់ឈ្មោះដល់មនុស្សដែលត្រូវទទួលបានការការពារយ៉ាងជាក់លាក់។ មិនត្រឹមតែចំពោះក្រុមមនុស្សស្រឡាញ់ភេទដូចគ្នា (LGBTI) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជនដែលមានពិការភាពផងដែរ ដែលបច្ចុប្បន្ននេះពួកគាត់ត្រូវបានការពារដោយអនុសញ្ញាដោយឡែក ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៦។ មនុស្សចាស់ ក៏អាចទទួលបានការការពារតាមរយៈអនុសញ្ញាមួយទៀតផងដែរ។ ជនជាតិដើមភាគតិច។ ជនជាតិភាគតិចគ្រប់ប្រភេទ។ មនុស្សគ្រប់រូប។

យេនឌ័រ គឺជាទស្សនទានដែលត្រូវបានលើកនិយាយស្ទើរតែគ្រប់មាត្រានៃសេចក្តីប្រកាសនេះ។ សម្រាប់ពេលវេលារបស់វា ឯកសារនេះនៅមានភាពខ្វះចន្លោះគួរឲ្យកត់សម្គាល់ចំពោះការប្រើប្រាស់ភាសាបែបប្រកាន់ភេទ។ ឯកសារនេះ សំដៅទៅលើ «មនុស្សគ្រប់រូប» «ទាំងអស់» ឬ «គ្មាននរណាម្នាក់» នៅទូទាំងមាត្រា ទាំង ៣០ នៃឯកសារនេះ។

ការប្រើប្រាស់នវានុវត្តនេះ ឆ្លុះបញ្ចាំងពីការពិតដែលថា ជាលើកដំបូងនៅក្នុងប្រវត្តិសាស្ត្រនៃការបង្កើតច្បាប់អន្តរជាតិ ស្ត្រីបានដើរតួនាទីដ៏សំខាន់ ក្នុងការតាក់តែងសេចក្តីប្រកាសជាសកលនេះ។

តួនាទីរបស់លោកស្រី អេលេនរ៍ រ៉ូស្វេលត៍ (Eleanor Roosevelt) ដែលជាប្រធានគណៈកម្មាធិការព្រាងគឺជាមនុស្សដែលមានឈ្មោះល្បី។ ហេតុការណ៍ដែលមិនសូវល្បីនោះគឺថាស្ត្រីមកពីប្រទេសដាណឺម៉ាក ប៉ាគីស្ថាន ប្លុកកុម្មុយនិស្ត និងបណ្តាប្រទេសដទៃទៀតនៅជុំវិញពិភពលោកជាច្រើន ក៏បានរួមចំណែកយ៉ាងសំខាន់ផងដែរនៅក្នុងការតាក់តែងឯកសារនេះ។

ជាការពិតណាស់ សូមអរគុណជាចម្បងចំពោះអ្នកតាក់តែងជនជាតិឥណ្ឌាឈ្មោះ ហាន់សា មេត្តា (Hansa Mehta) ដែលប្រយោគជាភាសាបារាំងថា «មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាព» ដែលបានដកស្រង់ចេញឯកសារដែលមានចំណងជើងថាសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សនិងសិទ្ធិពលរដ្ឋ (*Déclaration des droits de l'homme et du citoyen)* បានក្លាយជាសេចក្តីប្រកាសជាសកលថា

«មនុស្សគ្រប់រូបកើតមកមានសេរីភាព និងសមភាព»។

សាមញ្ញប៉ុន្តែ - ក្នុងន័យនៃសិទ្ធិស្ត្រី និងសិទ្ធិជនជាតិភាគតិច - ជាប្រយោគមួយបែបបដិវត្តន៍។

លោកស្រី ហាន់សា មេត្តា (Hansa Mehta) បានជំទាស់ទៅនឹងការអះអាងរបស់លោកស្រី អេលេន័រ រ៉ូស្វេលត៍ (Eleanor Roosevelt) ថា ពាក្យ "បុរស" ត្រូវបានគេយល់ថា រួមបញ្ចូលទាំងស្ត្រី ដែលជាគោលគំនិតមួយដែលត្រូវបានគេទទួលយកយ៉ាងទូលំទូលាយនៅពេលនោះ។ លោកស្រីបានអះអាងថា ប្រទេសនានាអាចប្រើពាក្យនេះ ដើម្បីរឹតបន្តឹងសិទ្ធិរបស់ស្ត្រី ច្រើនជាងការពង្រីកសិទ្ធិរបស់ពួកគាត់។

កើតមានក្រោយពីការបំផ្លិចបំផ្លាញនៃសង្គ្រាមលោកទាំងពីរលើក ការធ្លាក់ចុះដ៏មហិមានៅទសវត្ស ឆ្នាំ១៩៣០ និងការបំផ្លិចបំផ្លាញហូឡូខូស សេចក្តីប្រកាសជាសកលនៃផ្តោតលើការទប់ស្កាត់គ្រោះមហន្តរាយស្រដៀងគ្នានេះ អំណាចផ្តាច់ការ និងការរំលោភបំពាននានា ដែលបានបណ្តាលឲ្យកើតមានគ្រោះមហន្តរាយទាំងនោះ។ ឯកសារនេះ ចែងពីវិធីផ្សេងៗ ក្នុងការរារាំងយើងមិនឲ្យបន្តធ្វើបាបគ្នាទៅវិញទៅមក ហើយមានគោលបំណងផ្តល់ឲ្យយើងនូវ «សេរីភាពរួចផុតពីការភ័យខ្លាច និងទុគ៌តភាព»។

ឯកសារនេះ កំណត់ព្រំដែនទៅលើអ្នកមានអំណាច ហើយបំផុសក្តីសង្ឃឹមក្នុងចំណោមអ្នកគ្មានអំណាច។

ក្នុងរយៈពេលប្រាំពីរទសវត្សចាប់តាំងពីការអនុម័តឯកសារនោះ សេចក្តីប្រកាសជាសកលបានគាំទ្រការផ្លាស់ប្តូរដ៏មានប្រយោជន៍ជាច្រើនរាប់មិនអស់ នៅក្នុងជីវិតរស់នៅរបស់មនុស្សរាប់លាននាក់នៅទូទាំងពិភពលោក ដែលបានបញ្ចូលក្នុងរដ្ឋធម្មនុញ្ញជាតិប្រមាណជា ៩០ ប្រទេស និងច្បាប់និងស្ថាប័នជាតិជាតិ ថ្នាក់តំបន់ និងអន្តរជាតិជាច្រើន។

ប៉ុន្តែ ៧០ ឆ្នាំ បន្ទាប់ពីឯកសារនេះត្រូវបានអនុម័ត ការងារដែលសេចក្តីប្រកាសជាសកល ត្រូវបានដាក់ឲ្យយើងធ្វើគឺនៅឆ្ងាយណាស់។ ហើយវានឹងមិនមានឡើយ។

នៅក្នុងមាត្រាទាំង ៣០ ដែលភ្លឺថ្លាដូចគ្រីស្តាល សេចក្តីប្រកាសជាសកល បង្ហាញឲ្យយើងឃើញពីវិធានការនានាដែលនឹងបញ្ចប់ភាពក្រីក្រខ្លាំង និងផ្តល់ស្បៀងអាហារ ផ្ទះស្នាក់នៅ សុខភាព ការអប់រំ ការងារ និងឱកាសសម្រាប់មនុស្សគ្រប់រូប។

ឯកសារនេះបំភ្លឺផ្លូវយើងទៅកាន់ពិភពលោកមួយ ដែលគ្មានសង្គ្រាម និងការសម្លាប់រង្គាល ដោយគ្មានការធ្វើទារុណកម្ម ទុរ្ភិក្ស ឬអំពើអយុត្តិធម៌។ អ្វីដែលឯកសារនេះចង់បានគឺពិភពលោកមួយដែលទុក្ខវេទនាត្រូវបានកាត់បន្ថយ ហើយគ្មាននរណាម្នាក់ជាអ្នកមាន ឬអ្នកមានអំណាចខ្លាំង អាចគេចវេះពីយុត្តិធម៌បានឡើយ។

ជាពិភពលោកមួយ ដែលមនុស្សគ្រប់រូបមានតម្លៃដូចគ្នានឹងមនុស្សគ្រប់រូបដទៃទៀតដែរ មិនត្រឹមតែមានជាប់ពីកំណើតប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់រយៈពេលនៃជីវិតរស់នៅទាំងមូលរបស់គេផងដែរ។

អ្នកតាក់តែងឯកសារនេះ មានមានបំណងបង្ការទប់ស្កាត់សង្គ្រាមមួយទៀត ដោយដោះស្រាយនូវមូលហេតុដែលជាឫសគល់របស់វា ដោយការកំណត់សិទ្ធិមនុស្សគ្រប់គ្នានៅលើភពផែនដី អាចរំពឹង ហើយគ្រាន់តែទាមទារនូវអ្វីដែលពួកគេមាន ហើយដើម្បីបញ្ជាក់ពាក្យពេចន៍ច្បាស់លាស់មិនស្រពេចស្រពិល អំពីអ្វីដែលមិនអាចធ្វើបានសម្រាប់មនុស្សជាតិឡើយ។

មិនថាជនក្រីក្រ អ្នកស្រេកឃ្លាន ជនចំណាកស្រុក ឬជនបាត់បង់ឱកាសឡើយ អ្នកតាក់តែងបានមានគោលដៅបង្កើតប្រព័ន្ធ គាំទ្រនិងការពារពួកគេ។

សិទ្ធិទទួលបានស្បៀងអាហារ និងសិទ្ធិទទួលបានការអភិវឌ្ឍគឺមានសារៈសំខាន់ណាស់។ ប៉ុន្តែរឿងនេះ ត្រូវតែសម្រេចបានដោយគ្មានការរើសអើងឈរលើមូលដ្ឋានពូជសាសន៍ ភេទ ឬស្ថានភាពដទៃផ្សេងទៀត។ អ្នកមិនអាចនិយាយទៅកាន់ប្រជាជនរបស់អ្នកថា ខ្ញុំនឹងចិញ្ចឹមអ្នក ប៉ុន្តែខ្ញុំនឹងមិនឲ្យអ្នកនិយាយ ឬប្រតិបត្តិសាសនា ឬវប្បធម៌របស់អ្នកឡើយ។

សិទ្ធិដីធ្លី និងលំនៅដ្ឋានសមរម្យ គឺជាមូលដ្ឋានដាច់ខាត ហើយតែនៅប្រទេសមួយចំនួន វិធានការរឹតត្បិតគឺកំពុងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទាំងនោះ ចំពោះអ្នកដែលងាយរងគ្រោះបំផុត។

ការផ្លាស់ប្តូរអាកាសធាតុ អាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានស្បៀងអាហារ ជម្រក និងសុខភាព។ ទាំងនេះសុទ្ធតែពាក់ព័ន្ធទាំងអស់ ហើយសេចក្តីប្រកាសជាសកល និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ផ្តល់នូវផែនទីបង្ហាញផ្លូវដើម្បីសម្រេចសមិទ្ធផលបាន។

ខ្ញុំជឿជាក់ថាគោលការណ៍សិទ្ធិមនុស្សដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍នេះ គឺការរីកចម្រើនមួយដ៏ល្អបំផុតបែបស្ថាបនានៃគោលគំនិតក្នុងប្រវត្តិសាស្រ្តមនុស្សជាតិ ក៏ដូចជាជោគជ័យមួយដ៏ធំធេងបំផុតផងដែរ។

ប៉ុន្តែសព្វថ្ងៃនេះ ការរីកចម្រើននោះ បាននិងកំពុងរងការគំរាមកំហែង។

យើងកើតមកមាន «សេរីភាព និងសមភាព» ប៉ុន្តែមានមនុស្សរាប់លាននាក់នៅលើភពផែនដីនេះ មិនមានសេរីភាព និងសមភាពទេ។ សេចក្តីថ្លៃថ្នូររបស់ពួកគេ ត្រូវបានជាន់ឈ្លី ហើយសិទ្ធិរបស់ពួកគេ ត្រូវបានរំលោភបំពានជារៀងរាល់ថ្ងៃ។

នៅក្នុងប្រទេសជាច្រើន ការទទួលស្គាល់ជាមូលដ្ឋានថា មនុស្សគ្រប់រូបមានសមភាព និងមានសិទ្ធិជាប់ពីកំណើត ត្រូវបានគេយាយី។ ស្ថាប័ននានាដែលបង្កើតឡើងយ៉ាងតឹងរ៉ឹងដោយរដ្ឋនានា ដើម្បីសម្រេចបាននូវដំណោះស្រាយរួម ចំពោះបញ្ហារួម បាននិងកំពុងត្រូវបានគេធ្វើឲ្យថមថយ។

ហើយបណ្តាញទូលំទូលាយនៃច្បាប់អន្តរជាតិ ច្បាប់តំបន់ និងច្បាប់ជាតិ និងសន្ធិសញ្ញាដែលផ្តល់ធ្មេញដល់ចក្ខុវិស័យនៃសេចក្តីប្រកាសជាសកលក៏ត្រូវបានកាត់ផ្តាច់ ដោយរដ្ឋាភិបាល និងអ្នកនយោបាយដែលផ្តោតតែលើផលប្រយោជន៍ជាតិនិយមចង្អៀតចង្អល់។

យើងទាំងអស់គ្នា ត្រូវក្រោកឈរឡើងប្រកបថាមពលខ្លាំងឡើងថែមទៀត ដើម្បីសិទ្ធិទាំងឡាយ ដែលបានបង្ហាញដល់យើងគ្រប់គ្នាគួរមាន មិនត្រឹមតែខ្លួនយើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់មនុស្សទាំងឡាយដូចជាយើងផងដែរ ហើយដែលយើងមានហានិភ័យជារៀងរហូត ដោយការបាត់បង់សិទ្ធិតាមរយៈខ្លួនយើងផ្ទាល់ និងការភ្លេចភ្លាំង ការធ្វេសប្រហែស ឬការមិនយកចិត្តទុកដាក់របស់មេដឹកនាំយើង។

ខ្ញុំនឹងបញ្ចប់ នៅត្រង់កន្លែងដែលសេចក្តីប្រកាសជាសកលចាប់ផ្តើម ដោយមានការសន្យាដ៏មានឥទ្ធិពល និងការក្រើនរំលឹក ដែលមានចែងនៅក្នុងបន្ទាត់ដំបូងនៃបុព្វកថារបស់សេចក្តីប្រកាសនេះ៖

> «...ការទទួលស្គាល់សេចក្តីថ្លៃថ្នូរជាប់ពីកំណើត និងសិទ្ធិស្មើភាពគ្នា និងសិទ្ធិមិន អាចលក់ ដូរ ផ្ទេរ ឬដកហូតបានរបស់សមាជិកទាំងអស់នៃគ្រួសារមនុស្ស គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅលើពិភពលោក»។

> "...ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្ស នាំឱ្យមានអំពើ ព្រៃផ្សៃសាហាវយង់ឃ្នង ធ្វើឱ្យក្តៅក្រហាយដល់សតិសម្បជញ្ញៈមនុស្សជាតិ និងថា ការឈានដល់ពិភពលោកមួយដែលមនុស្សទាំងឡាយមានសេរីភាពក្នុងការនិយាយស្តី និងជំនឿ និងភាពរួចផុតពីការភ័យ ខ្លាច និងទុគ៌តភាព ត្រូវបានប្រកាសថាជាសេចក្តីប្រាថ្នាដ៏ខ្ពស់បំផុតរបស់មនុស្សទូទៅ។

> «...ជាការចាំបាច់ ដែលសិទ្ធិមនុស្សត្រូវតែបានការពារដោយនីតិរដ្ឋ ដើម្បីជៀសវាងកុំឱ្យមនុស្សបង្ខំចិត្តជាចុងក្រោយបង្អស់ បះបោរប្រឆាំងទល់នឹងអំណាចផ្តាច់ការ និងការគាបសង្កត់»។

ហើយយើងគួរតែយកចិត្តទុកដាក់បន្ថែមទៀតចំពោះពាក្យចុងក្រោយនៃបុព្វកថាដដែលនោះ ៖

> « ...បុគ្គលគ្រប់ៗរូប និងអង្គការសង្គមទាំងអស់ ដោយ រក្សាខ្ជាប់ជានិច្ចក្នុងស្មារតីរបស់ខ្លួន នូវសេចក្តីប្រកាសនេះ ខិតខំប្រឹងប្រែងបណ្តុះបណ្តាលការគោរពសិទ្ធិ និងសេរីភាពទាំងនេះ តាមរយៈការបង្រៀននិងការអប់រំ ហើយនិងខំប្រឹងប្រែងធានាឱ្យមានការទទួល ស្គាល់ និងការអនុវត្តជាសកល និងដោយស័ក្តិសិទ្ធិ នូវសិទ្ធិនិងសេរីភាព ដោយវិធានការជាតិ និងអន្តរជាតិ ដែលមានលក្ខណៈរីកចម្រើនជាលំដាប់ ទាំងក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិក ទាំងក្នុងចំណោម ប្រជាពលរដ្ឋដែនដីដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃរដ្ឋទាំងនោះ។"

យើងបានដើរផ្លូវដ៏វែងឆ្ងាយតាមផ្លូវនេះ តាំងពីឆ្នាំ១៩៤៨។ យើងបានចាត់វិធានការជាបណ្តើរៗជាច្រើនរហូតមក ដូចដែលបានបរិយាយដោយសេចក្តីប្រកាសជាសកល នៅថ្នាក់ជាតិ និងឆាកអន្តរជាតិ។

ប៉ុន្តែយើងនៅមានផ្លូវដ៏វែងឆ្ងាយដែលត្រូវដើរ ហើយមេដឹកនាំជាច្រើនលើសលុបរបស់យើង ហាក់ដូចជាបានភ្លេចពាក្យសម្តីនិងពាក្យទំនាយដ៏មានឥទ្ធិពលទាំងនេះ។ យើងត្រូវកែតម្រូវមិនត្រឹមតវិយាបថនេះ មិនត្រឹមតែនៅថ្ងៃនេះទេ មិនត្រឹមតែនៅខួបគម្រប់៧០ ឆ្នាំ នៅថ្ងៃច័ន្ទក្រោយប៉ុណ្ណោះទេ ប៉ុន្តែគឺជារៀងរាល់ថ្ងៃ រាល់ឆ្នាំ។

អ្នកការពារសិទ្ធិមនុស្សនៅលើពិភពលោកទាំងមូល ស្ថិតនៅលើខ្សែត្រៀមជួរមុខនៃការការពារសេចក្តីប្រកាសជាសកលតាម រយៈការងាររបស់ពួកគេ ការខិតខំប្រឹងប្រែងរបស់ពួកគេ និងការលះបង់របស់ពួកគេ។ មិនថាយើងរស់នៅទីណា ឬស្ថានភាពរបស់យើងបែបណានោះទេ យើងភាគច្រើនមានអំណាចធ្វើឲ្យមានភាពខុសគ្នា - ដើម្បីធ្វើឲ្យផ្ទះ សហគមន៍ ប្រទេសរបស់យើង និងពិភពលោករបស់យើងកាន់តែប្រសើរឡើង - ឬកាន់តែអាក្រក់ - សម្រាប់អ្នកដទៃ។ យើងម្នាក់ៗត្រូវធ្វើផ្នែករបស់យើង ដើម្បីធ្វើឲ្យជីវិតរស់នៅរបស់យើងក្លាយជាសុបិនដ៏ស្រស់ស្អាតនៃសេចក្តីប្រកាសជាសកល។

ដោយសារតែឯកសារនេះ គឺជាអំណោយរបស់បុព្វបុរសយើង ជួយយើងកុំឲ្យចៀសផុតពីអ្វីៗដែលពួកគេបានឆ្លងកាត់ ។

**ចប់**

*សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ត្រូវបានមហាសន្និបាត អ.ស.ប អនុម័តនៅវិមាន Palais de Chaillot នាទីក្រុងប៉ារីស បីឆ្នាំបន្ទាប់ពីសង្គ្រាមលោកលើកទី២ បានបញ្ចប់។ សេចក្តីប្រកាសនេះ គឺជាផលិតផលកើតចេញពីការងាររយៈពេល ១៨ ខែ របស់គណៈកម្មាធិការតាក់តែង ដែលមានសមាជិក និងអ្នកផ្តល់យោបល់មកពីទូទាំងពិភពលោក ហើយតាមពាក្យសំដីរបស់ស្ថាបត្យករសំខាន់ម្នាក់គឺលោក រ៉េនេ កាស្សីន (René Cassin) "នៅចុងបញ្ចប់នៃសម័យប្រជុំមួយរយលើក ដែលមានជាញឹកញយ តែងមានការពិភាក្សាដ៏ក្តៅគគុក ត្រូវបានអនុម័តនៅក្នុងទម្រង់នៃមាត្រាចំនួន ៣០ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។*

***ដើម្បីមើលតាមលំដាប់លំដោយនៃអត្ថបទខ្លីទាំង៣០ មាត្រានីមួយៗនៃមាត្រាទាំង៣០ នៃសេចក្តីប្រកាសជាសកល៖*** https://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=23871&LangID=E

***ព័ត៌មានលម្អិតបន្ថែមអំពីព្រឹត្តិការណ៍ និងយុទ្ធនាការនានាដែលទាក់ទងនឹងខួបគម្រប់ ៧០ ឆ្នាំ នៃសេចក្តីប្រកាសនេះ អាចចូលទៅកាន់៖*** http://www.standup4humanrights.org/

***សម្រាប់ព័ត៌មានបន្ថែមអំពីសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) ផ្ទាល់ សូមចូលទៅកាន់៖***
http://www.un.org/en/universal-declaration-human-rights/

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក រ៉ូភើត ខូលវិល (Rupert Colville) តាមរយៈទូរស័ព្ទលេខ៖ + ៤១ ២២ ៩១៧ ៩៧៦៧/ rcolville@ohchr.org ឬលោកស្រី រ៉ាវីណា សេមសាដានី (Ravina Shamdasani) តាមរយៈទូរស័ព្ទលេខ៖ ៤១ ២២ ៩១៧ ៩១៦៩/ rshamdasani@ohchr.org ឬលោកស្រី ម៉ារតា ហ៊ូរតាឌូ (Marta Hurtado) តាមរយៈទូរស័ព្ទលេខ៖ ៤១ ២២ ៩១៧ ៩៤៦៦ / mhurtado@ohchr.org*

***ថេក និងស៊ែរ - ទ្វីតធឺ ៖ @UNHumanRights និង ហ្វេសប៊ុក៖ unitednationshumanrights***